# ព្រឹត្តិបត្រព័ត៌មាន

គម្រោងអភិវឌ្ឍន៍សុខភាពសិក្សាសម្រាប់កុមារកម្ពុជា

លេខ ២៨ | ថ្ងៃអង្គារ ១១កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹង ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៥

## ពិធីបិទបញ្ចប់ «គម្រោងអភិវឌ្ឍន៍សុខភាពសិក្សាសម្រាប់កុមារកម្ពុជា ដំណាក់កាលទី ១ (២០២០-២០២៥)» ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា








នាព្រឹកថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៥ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានអញ្ជើញជាអធិបតីក្នុងពិធីបិទបញ្ចប់គម្រោងអភិវឌ្ឍន៍សុខភាពសិក្សាសម្រាប់កុមារកម្ពុជា របស់សាកលវិទ្យាល័យ តូក្យូ ហ្គាគីហ្គេ នៃប្រទេសជប៉ុន ដំណាក់កាលទី ១ (២០២០-២០២៥) និងមានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា លោក ARIKAWA TAKASHI នាយកប្រតិបត្តិនៃ មូលនិធិនីបប៉ុន (The Nippon Foundation) សាស្ត្រាចារ្យបណ្ឌិត ASAKURA TAKASHI ប្រធានគម្រោង SHCC នាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងបាត់ដំបង សាស្ត្រាចារ្យពី សាកលវិទ្យាល័យ តូក្យូ ហ្គាគីហ្គេ និងសាកលវិទ្យាល័យដៃគូ អង្គការនិងដៃគូពាក់ព័ន្ធ និងមន្ត្រីក្រោមឱវាទ។







**Published Article:** https://central.ams.com.kh/detail/1276725 ***12 December 2025 | Phnom Penh***

# របាយការណ៍ និងប្រសាសន៍សំណេះសំណាល ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា


H.E. Academician HANG CHUON NARON,
Deputy Prime Minister, Minister of Education, Youth and Sport.

ក្នុងឱកាសនេះ**ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់មូលនិធិនីបប៉ុន សាស្ត្រាចារ្យប្រធានគម្រោង និងភាគីពាក់ព័ន្ធទាំងអស់ដែលបានសម្រេចបាននូវគម្រោងនេះ ដែលបានជួយលើកកម្ពស់សុខភាពកុមារ និងលទ្ធផលសិក្សាឱ្យទទួលបានលទ្ធផលជាវិជ្ជមាន។ គម្រោងអភិវឌ្ឍន៍សុខភាពសិក្សាសម្រាប់កុមារកម្ពុជា (SHCC) ដឹកនាំដោយសាកលវិទ្យាល័យ តូក្យូ ហ្គាគីហ្គេ នៃប្រទេសជប៉ុនក្រោមកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធរួមមាន នាយកដ្ឋានសុខភាពសិក្សា វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងវិទ្យាស្ថានគរុកោសល្យបាត់ដំបង ក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា និងការគាំទ្រដ៏ថ្លៃថ្លារបស់មូលនិធិនីបប៉ុន បានអនុវត្ត និងបញ្ចប់ដោយភាពជោគជ័យ។ ហើយសូមបញ្ជាក់ដែរថា គម្រោងនេះរៀបចំឡើងក្នុងគោលបំណង៖ ការគាំទ្រដល់ការអភិវឌ្ឍន៍វគ្គសិក្សាសុខភាពសិក្សា និងមុខវិជ្ជាសិក្សានៅគ្រឹះស្ថានឧត្តមសិក្សារួមមាន វិទ្យាស្ថានគរុកោសល្យ សាលាគរុកោសល្យ និងវិក្រឹត្យការ។ ការផ្តល់ការបណ្តុះបណ្តាលសុខភាពសិក្សាដល់គ្រូនៅមូលដ្ឋាន បឋមសិក្សា និងមធ្យមសិក្សា និងការលើកកម្ពស់សកម្មភាពសុខភាពសិក្សា។ ការប្រមូលទិន្នន័យ និងការតាមដានដំណើរការសិក្សា និងការស្រាវជ្រាវតាមភាពចាំបាច់ ដើម្បីបង្កើតសៀវភៅសិក្សាគោល និង ការផ្តល់ក្នុងការបណ្តុះបណ្តាលសុខភាពសិក្សាដល់គ្រូឧទ្ទេស។ រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញចក្ខុវិស័យក្នុងការប្រែក្លាយទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់ក្នុងឆ្នាំ២០៥០ តាមរយៈការកំណត់សំណុំយុទ្ធសាស្ត្រ ដើម្បីអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព ផលិតភាពការងារខ្ពស់ និងសុខភាពរឹងមាំ។ ក្នុងបរិបទនេះ ការលើកកម្ពស់សុខភាពសិក្សា គឺជាកត្តាដ៏សំខាន់ និងមិនអាចខ្វះបានក្នុងការចូលរួមចំណែកដល់ការធានាបាននូវការសិក្សារបស់សិស្សប្រកបដោយគុណភាព និងបង្កើនអត្រាបញ្ចប់ការសិក្សារបស់ពួកគេ ដើម្បីឈានទៅដល់ការសម្រេចគោលដៅនៃការអប់រំ និងចក្ខុវិស័យរបស់ជាតិ។ សុខភាព គឺជាកត្តាស្នូលក្នុងការកំណត់ការសិក្សារបស់សិស្ស និងជាមូលដ្ឋានសម្រាប់ ការអភិវឌ្ឍសង្គមជាតិ ប្រកបដោយចីរភាព។ ដោយមើលឃើញពីទំនាក់ទំនងយ៉ាងជិតស្និទ្ធ រវាងសុខភាព និងការអប់រំ ការដាក់បញ្ចូលមុខវិជ្ជាសុខភាពសិក្សា ទៅក្នុងកម្មវិធីអប់រំគ្រូបង្រៀន គឺជាជំហានដ៏សំខាន់ក្នុងការអប់រំគរុនិស្សិត ដែលអនាគតនឹងក្លាយជាគ្រូបង្រៀន ឱ្យទទួលបាននូវ វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដែលចាំបាច់ក្នុងការជំរុញសុខុមាលភាពរបស់សិស្សនៅក្នុងថ្នាក់រៀន និងសហគមន៍ឱ្យល្អប្រសើរ។

ជាថ្មីម្តងទៀត តាងនាមក្រសួងអប់រំ យុវជន និងកីឡា ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ គម្រោងអភិវឌ្ឍន៍សុខភាពសិក្សាសម្រាប់កុមារកម្ពុជា(SHCC)ដឹកនាំដោយសាស្ត្រាចារ្យបណ្ឌិត Asakura Takashi និងក្រុមសាស្ត្រាចារ្យមកពីសាកលវិទ្យាល័យ តូក្យូ ហ្គាគីហ្គេ និងសាស្ត្រាចារ្យនៅសាកលវិទ្យាល័យដៃគូ ៤ ទៀតរួមមាន សាកលវិទ្យាល័យIbaraki សាកលវិទ្យាល័យJumonji សាកលវិទ្យាល័យSaitama និងសាកលវិទ្យាល័យជាតិYokohama នៃប្រទេសជប៉ុន ដែលបានរៀបចំតាក់តែងសៀវភៅសិក្សាគោលមុខវិជ្ជាសុខភាពសិក្សានេះឡើង និងសូមថ្លែងអំណរគុណចំពោះកិច្ចសហការដ៏ល្អពីថ្នាក់ដឹកនាំ និងមន្ត្រីនៃនាយកដ្ឋានសុខភាពសិក្សា រួមជាមួយគណៈគ្រប់គ្រង និងគ្រូឧទ្ទេស នៃវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងបាត់ដំបង ដែលបានខិតខំប្រឹងប្រែងអស់ពីលទ្ធភាព និងសមត្ថភាពក្នុងការអនុវត្តគម្រោង SHCC ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងសម្រេចបាននូវសមិទ្ធផលជាផ្លែផ្កា៕



# របាយការណ៍ស្វាគមន៍សង្ខេប ដោយប្រធានគម្រោង SHCC

សាស្ត្រាចារ្យបណ្ឌិត **ASAKURA TAKASHI** ប្រធានគម្រោង SHCC។ គម្រោង SHCC ដំណាក់កាលទី១ បានបញ្ចប់ដោយជោគជ័យរយៈពេលប្រមាណជិតប្រាំពីរឆ្នាំ (២០១៩–២០២៥) អនុវត្តដោយ សាកលវិទ្យាល័យ Tokyo Gakugei និងមានការឧបត្ថម្ភពីមូលនិធិនីបប៉ុន។ គម្រោងនេះបានចាប់ផ្តើមពីគំនិតផ្តួចផ្តើមតូចមួយ មុននឹងអភិវឌ្ឍឡើងជាក្របខ័ណ្ឌសហការដែលមានរចនាសម្ព័ន្ធច្បាស់លាស់ជាមួយ PTEC និង BTEC ហើយមានការចូលរួម និងការគាំទ្រយ៉ាងសកម្មពីបុគ្គលិកក្នុងស្រុក និងអ្នកជំនាញជនជាតិជប៉ុន។ ទោះបីជាគម្រោងបានប្រឈមមុខនឹងបញ្ហាប្រឈមធ្ងន់ធ្ងរពីជំងឺរាតត្បាត COVID-19 ក៏ដោយ ក៏គម្រោងនៅតែអាចបន្តអនុវត្ត និងសម្រេចលទ្ធផលបានដោយជោគជ័យ តាមរយៈការសហការយ៉ាងជិតស្និទ្ធ និងមានប្រសិទ្ធភាពរវាងភាគីពាក់ព័ន្ធទាំងអស់។ គម្រោងបានអនុវត្តដោយផ្អែកលើទម្រង់ "middle-up និង middle-down" ដែលផ្តោតសំខាន់លើការកែលម្អវិទ្យាស្ថានគរុកោសល្យ ជាគ្រឹះស្នូលសម្រាប់ការលើកកម្ពស់ និងធានាបាននូវការកែលម្អសុខភាពសិក្សាប្រកបដោយចីរភាព។ សមិទ្ធផលសំខាន់ៗរបស់គម្រោងរួមមាន ការអភិវឌ្ឍនិងកសាងសៀវភៅសិក្សាគោលសុខភាពសិក្សាសម្រាប់បឋមសិក្សា ចំនួន២ ក្រេឌីត និងសៀវភៅមគ្គុទេសក៍សម្រាប់គ្រូបង្រៀន។ គម្រោងក៏បានបង្កើនសមត្ថភាពគ្រូឧទ្ទេសតាមរយៈការបណ្តុះបណ្តាលចំនួន ២៥ វគ្គនៅប្រទេសកម្ពុជា និង ៤ វគ្គនៅប្រទេសជប៉ុន។ រហូតដល់ពេលនេះមាន គរុនិស្សិតចំនួន ១,២០០ នាក់ បានសិក្សាមុខវិជ្ជាសុខភាពសិក្សា នៃគរុនិស្សិតទាំង៤ជំនាន់ ហើយក្នុងចំណោមនេះ មាន ៩០០ នាក់ (គរុនិស្សិតពីជំនាន់ទី១ ដល់ទី៣)បានបញ្ចប់វគ្គសិក្សា និងកំពុងបង្រៀននៅទូទាំងប្រទេសកម្ពុជា ដោយមានសមត្ថភាពក្នុងការបង្រៀនមុខវិជ្ជាសុខភាពសិក្សា។



Mr. ASAKURA TAKSHI, Project Leader of SHCC





នៅឆ្នាំ ២០២៦ នឹងបន្តសកម្មភាពក្រោមអង្គការថ្មីមួយឈ្មោះ STEP (School Health Training and Ecohealth Promotion Foundation) ដែលនឹងបន្តអនុវត្តគម្រោង SHCC ដំណាក់កាលទី២ ក្រោមការឧបត្ថម្ភពីមូលនិធិនីបប៉ុន (The Nippon Foundation) ក្នុងគោលបំណងអភិវឌ្ឍន៍ និងដាក់ឱ្យអនុវត្តមុខវិជ្ជាឯកទេសសុខភាពសិក្សា នៅកម្រិតមធ្យមសិក្សាបឋមភូមិ តាមរយៈ PTEC និង BTEC។

# ចំណាប់អារម្មណ៍ដោយនាយកប្រតិបត្តិ មូលនិធិនីបប៉ុន


Mr. TAKASHI ARIKAWA, Executive Director
The Nippon Foundation





លោក **ARIKAWA TAKASHI** នាយកប្រតិបត្តិនៃនាយកដ្ឋានកិច្ចការអន្តរជាតិ នៃមូលនិធិនីបប៉ុន បានបង្ហាញពីភាពជោគជ័យក្នុងការបញ្ចប់គម្រោង SHCC ដំណាក់កាលទី១ (២០២០–២០២៥)។ លោកបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ ក្រសួងអប់រំ យុវជន និងកីឡា វិទ្យាស្ថានគរុកោសល្យ ដៃគូរគម្រោង និងភាគីពាក់ព័ន្ធទាំងអស់ សម្រាប់ការសហការ និងការប្តេជ្ញាចិត្តដ៏រឹងមាំ។ លោក អារិកាវ៉ា បានបញ្ជាក់ថា គម្រោង SHCC បានលើកកម្ពស់ការបណ្តុះបណ្តាលគរុនិស្សិតសម្រាប់មុខវិជ្ជាសុខភាពសិក្សា ដែលជាគ្រឹះសម្រាប់ការអប់រំដែលមានគុណភាព និងកសាងគ្រូបង្រៀននៅកម្ពុជា។ សម្រាប់ ដំណាក់កាលទី២ (២០២៦–២០២៨) ដែលនឹងចាប់ផ្តើមនៅខែមករា ឆ្នាំ២០២៦ លោកបានបន្តថា៖ ភាគីខាងក្រៅអាចផ្តល់បានតែជម្រើសផ្នែកបច្ចេកទេស និងចំណេះដឹងប៉ុណ្ណោះ។ សម្រាប់ការអភិវឌ្ឍន៍អប់រំប្រកបដោយចីរភាព គឺសំខាន់ណាស់ដែលលោកអ្នកត្រូវរចនា និងអនុវត្តកម្មវិធីបណ្តុះបណ្តាលគ្រូ និងមេរៀនសុខភាពសិក្សាដែលមានលក្ខណៈខ្មែរជាមូលដ្ឋាន មិនមែនតាមបរិបទប្រទេសជប៉ុនឡើយ។ ជាចុងបញ្ចប់លោកបានបញ្ជាក់ពីការប្តេជ្ញាចិត្តក្នុងការលើកកម្ពស់គុណភាពអប់រំនៅកម្ពុជា និងសង្ឃឹមថាការសហការនឹងបន្តនៅដំណាក់កាលទី២បន្តទៀត។

# ពិធីប្រគល់សៀវភៅសិក្សាគោលសុខភាពសិក្សាសម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ



លោកសាស្ត្រាចារ្យបណ្ឌិត ASAKURA TAKASHI ប្រធានគម្រោង SHCC ប្រគល់សៀវភៅជូន **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**



**ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** ប្រគល់លិខិតថ្លែងអំណរគុណដល់ប្រធានគម្រោងSHCC



លោក ARIKAWA TAKASHI នាយកប្រតិបត្តិមូលនិធិនីប្ប៉ុន ប្រគល់សៀវភៅជូន **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**



**ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** ប្រគល់លិខិតថ្លែងអំណរគុណដល់ **នាយកប្រតិបត្តិមូលនិធិនីប្ប៉ុន**

**ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** ប្រគល់លិខិតថ្លែងអំណរគុណដល់ **ឯកឧត្តមបណ្ឌិត ជា វង្សា** នាយកវិទ្យាស្ថានគរុកោសល្យបាត់ដំបង





**ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** ប្រគល់លិខិតថ្លែងអំណរគុណដល់ **ឯកឧត្តមបណ្ឌិត សិត សេង** នាយកវិទ្យាស្ថានគរុកោសល្យភ្នំពេញ

# កំណត់ត្រានៃដំណើរ ៥ ឆ្នាំរបស់គម្រោង









វីដេអូបង្ហាញពីការប្តេជ្ញាចិត្ត និងសមិទ្ធផលរបស់ **លោក ហុង សុវណ្ណ** គ្រូឧទ្ទេសសុខភាពសិក្សានៃ PTEC និង **អ្នកស្រី ឡាំ ប៊ុនមករា** គ្រូឧទ្ទេសសុខភាពសិក្សានៃ BTEC។ ការចូលរួមយ៉ាងសកម្មរបស់គ្រូឧទ្ទេសទាំង២រូបក្នុងគម្រោង SHCC បានជួយពង្រឹងជំនាញបង្រៀន ជំនាញវិជ្ជាជីវៈ និងចំណេះដឹងផ្នែកអប់រំសុខភាព ដើម្បីលើកកម្ពស់សុខភាព សុវត្ថិភាព និងសុខុមាលភាពរបស់សិស្សានុសិស្សកម្ពុជា។ គ្រូឧទ្ទេសទាំង២រូប បានថ្លែងអំណរគុណចំពោះសាកលវិទ្យាល័យដៃគូ និងអង្គការគាំទ្រដែលបានចូលរួមក្នុងការអនុវត្តគម្រោងនេះដោយជោគជ័យ។

**ស្កេន QR សម្រាប់ទស្សនាវីដេអូ**

## របាយការណ៍សមិទ្ធផលៈ ២០២០ - ២០២៥




ទិដ្ឋភាពរួមក្នុងរបាយការណ៍ ៥ ឆ្នាំនៃគម្រោង SHCC បង្ហាញអំពីការអនុវត្តគម្រោងចាប់ពីឆ្នាំ ២០២០ ដល់ ២០២៥ ក្នុងគោលបំណងគាំទ្រវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងវិទ្យាស្ថានគរុកោសល្យបាត់ដំបង ក្នុងការដាក់បញ្ចូលមុខវិជ្ជាសុខភាពសិក្សាជាមុខវិជ្ជាថ្មី និងជាមុខវិជ្ជាគោល សម្រាប់ការបណ្តុះបណ្តាលគរុនិស្សិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ។ ក្នុងរយៈពេល ៥ ឆ្នាំ គម្រោង SHCC បានអនុវត្តសកម្មភាពសំខាន់ៗរួមមាន ការរៀបចំកម្មវិធីសិក្សាលម្អិត ការរៀបចំសៀវភៅសិក្សាគោល ការបណ្តុះបណ្តាលគ្រូឧទ្ទេសសុខភាពសិក្សា និងការគាំទ្រការបង្រៀននៅវិទ្យាស្ថានគរុកោសល្យ ដែលបានជួយធានាបាននូវការអនុវត្តមុខវិជ្ជាសុខភាពសិក្សាដោយមានប្រសិទ្ធភាព គុណភាព និងចីរភាព។

**ស្កេន QR សម្រាប់មើលរបាយការណ៍**

## បទបង្ហាញស្តីពី មុខវិជ្ជាសុខភាពសិក្សានៃវិទ្យាស្ថានគរុកោសល្យទាំងពីរ






បទបង្ហាញរបស់ **កញ្ញា លុក សូលីនដា** គ្រូឧទ្ទេសសុខភាពសិក្សានៃ PTEC ផ្តោតសំខាន់លើ កម្មវិធីសិក្សាលម្អិតនិងសៀវភៅសិក្សាគោលការគ្រប់គ្រងសុខភាពនិងសុខុមាលភាពរបស់គរុនិស្សិត វគ្គបណ្តុះបណ្តាលនិងទស្សនកិច្ចសិក្សា និងការគាំទ្រសាលាអនុវត្តន៍ទាំងពីរ។ បទបង្ហាញនេះមានគោលបំណងពង្រឹងសមត្ថភាព និងលើកកម្ពស់សុខភាព សុវត្ថិភាព និងសុខុមាលភាពរបស់គរុនិស្សិត។





**លោក ស្រី យីវសុខុម** គ្រូឧទ្ទេសមុខវិជ្ជាសុខភាពសិក្សា នៃវិទ្យាស្ថានគរុកោសល្យបាត់ដំបង បានធ្វើបទបង្ហាញយ៉ាងលម្អិតអំពីស្ថានភាពបច្ចុប្បន្ននៃមុខវិជ្ជាសុខភាពសិក្សា។ បទបង្ហាញនេះបានរៀបរាប់អំពីសកម្មភាពបណ្តុះបណ្តាលនានា បញ្ហាប្រឈម និងសំណូមពរ ព្រមទាំងផែនការបន្ត ដើម្បីពង្រឹងការអនុវត្តមុខវិជ្ជាសុខភាពសិក្សាឱ្យកាន់តែមានប្រសិទ្ធភាព និងចីរភាព។

## បទបង្ហាញពីផែនការបន្តស្តីអំពី «គម្រោងអភិវឌ្ឍន៍សុខភាពសិក្សាសម្រាប់កុមារកម្ពុជា ដំណាក់កាលទី២ (២០២៦ ~ ២០២៨)»

កញ្ញា MASUKO YUKA បានធ្វើបទបង្ហាញនូវព័ត៌មានទូទៅអំពីអង្គការ NGO STEP និងគម្រោងអភិវឌ្ឍន៍សុខភាពសិក្សាសម្រាប់កុមារកម្ពុជាដំណាក់កាលទី II (២០២៦–២០២៨) ដែលមានគោលបំណងលើកកម្ពស់ការអប់រំសុខភាពនៅសាលារៀនកម្ពុជា តាមរយៈការអភិវឌ្ឍមុខវិជ្ជាសម្រាប់បណ្តុះបណ្តាលគ្រូឧទ្ទេស និងកសាងសមត្ថភាពគ្រូឧទ្ទេសក្នុងការលើកកម្ពស់សុខភាព និងសុខុមាលភាពកុមារនៅកម្ពុជា។



## ប្រកាសបិទកម្មវិធីដោយ ឯកឧត្តមវេជ្ជបណ្ឌិត យង់ គន្ធារិទ្ធ អនុប្រធាននាយកដ្ឋានសុខភាពសិក្សា ក្រសួងអប់រំ យុវជន និងកីឡា









ក្រសួងអប់រំ យុវជន និងកីឡា ផ្តល់សារៈសំខាន់យ៉ាងខ្លាំងដល់សុខភាពសាលារៀន ជាវិស័យមួយដែលបន្តទទួលបានការយកចិត្តទុកដាក់ និងការប្តេជ្ញាចិត្តយ៉ាងខ្ពស់ពីឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ។ ការផ្តោតលើសុខភាពសាលារៀនត្រូវបានទទួលស្គាល់ថាជាគន្លងសំខាន់ក្នុងការកសាងសមត្ថភាពយុវជន និងការអប់រំប្រកបដោយចីរភាព។ ដោយផ្អែកលើបទពិសោធន៍ជាង ២០ឆ្នាំក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍ផ្សេងៗគម្រោង SHCC ត្រូវបានទទួលស្គាល់ថាជាគម្រោងមានលក្ខណៈពិសេសពិតប្រាកដ។ ក្រៅពីការរៀបចំវគ្គបណ្តុះបណ្តាលគ្រូចំនួន ២៥ លើកនៅប្រទេសកម្ពុជា និងកម្មវិធីបណ្តុះបណ្តាលនៅប្រទេសជប៉ុនចំនួន ៤ លើក គម្រោង SHCC មានលក្ខណៈពិសេសក្នុងការរួមបញ្ចូលការអប់រំជាគោលការណ៍ និងការអនុវត្តជាក់ស្តែង រួមទាំងបទពិសោធន៍ដោយផ្ទាល់។ ការរួមបញ្ចូលនេះធ្វើឱ្យគម្រោងមានភាពខុសប្លែកពីគម្រោងអប់រំផ្សេងៗ និងធានាបាននូវលទ្ធផលអាចប្រតិបត្តិបាននៅក្នុងបរិបទខ្មែរ។ បន្ថែមពីនេះ គម្រោង SHCC បានលើកកម្ពស់ស្មារតីសហការយ៉ាងរឹងមាំ និងបង្កើតសហគមន៍វិជ្ជាជីវៈមួយ ដែលរួបរួមគ្នា និងគាំទ្រគ្នាទៅវិញទៅមក។ គម្រោងនេះបានរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍគ្រូបង្រៀនឱ្យមានសមត្ថភាព និងចំណេះដឹងស្របតាមតម្រូវការនៃសតវត្សទី ២១។ ដោយសារការអនុវត្តគោលនយោបាយអប់រំជាតិឱ្យទទួលបានជោគជ័យ ពឹងផ្អែកលើធនធានមនុស្សដែលមានសមត្ថភាព និងការប្តេជ្ញាចិត្ត គម្រោង SHCC មានតួនាទីសំខាន់ក្នុងការជំរុញអាទិភាពជាតិលើសុខភាពសិក្សា និងការអប់រំយុវជនយ៉ាងច្បាស់។

# ពិធីចែកវិញ្ញាបនបត្រក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា




## វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ


លោកស្រី ហួ ឃីម


កញ្ញា លុក សូលីនដា


លោកស្រី ណាក់ ពេជ្រលក្ខ័ណា


លោកស្រី នូវ សុផល


លោក ហុង សុវណ្ណ


លោកស្រី ឆាយ បូនី


លោក ប៉ាល់ ចំរើន


កញ្ញា សាន ស្រីរី


លោកស្រី ហ៊ូ សៅម៉ូលីន


លោកស្រី ធុំ គន្ធី


លោក សេង សីហៈ

## វិទ្យាស្ថានគរុកោសល្យបាត់ដំបង


លោកស្រី ឡាំ ប៊ុនមករា


លោក ម៉ៅ វាសនា


លោក ស្រី ឃីវសុខុម


លោក ចាន់ រ៉ា


លោកស្រី សារី ម៉ូនីកា


លោកស្រី ហេង តុលា


លោកស្រី កែវ ស្មើ


លោកស្រី សារ សុមនា

## វីដេអូសង្ខេបអំពីព្រឹត្តិការណ៍សំខាន់ៗ ដែលបានប្រព្រឹត្តនៅក្នុងពិធីបិទ





ពិធីបិទគម្រោងអភិវឌ្ឍន៍សុខភាពសិក្សាសម្រាប់កុមារកម្ពុជា SHCC ដំណាក់កាលទី១ (២០២០–២០២៥) បានគូសបញ្ជាក់សមិទ្ធផលសំខាន់ៗ និងការរួមចំណែកដ៏មានតម្លៃពីដៃគូ និងភាគីពាក់ព័ន្ធក្នុងរយៈពេលប្រាំឆ្នាំ។ វីដេអូសង្ខេបនេះបង្ហាញពីព្រឹត្តិការណ៍សំខាន់ៗនិងការខិតខំប្រឹងប្រែងរួមគ្នា អំឡុងពេលបិទបញ្ចប់គម្រោងដោយជោគជ័យ ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**ស្កេន QR សម្រាប់ទស្សនាវីដេអូ** »

## រង្វាន់ឆ្នើមទាំង ៥ រូប សម្រាប់ការចូលរួមបានពេញលេញ



**លោក ម៉ៅ វាសនា** (BTEC)



**លោកស្រី ឡាំ ប៊ុនមករា** (BTEC)



**លោក ស្រី យីរសុខុម** (BTEC)



**កញ្ញា អ៊ុំ រិទ្ធស្សា** (PTEC)



**លោកស្រី ង៉ុំ គន្ធី** (PTEC)

**ការប្ដេជ្ញាចិត្តតាមរយៈការអនុវត្តជាក់ស្ដែង!** គម្រោង SHCC មានមោទភាពក្នុងការសម្រិតសម្រាំងគ្រូឧទ្ទេសឆ្នើម៥រូប ដែលបានចូលរួមវគ្គបណ្ដុះបណ្ដាលទាំង ២៥ វគ្គដោយស្មើរតែមិនខ្វះវគ្គណាមួយ។ ការប្ដេជ្ញា និងភាពស្អិតស្អែររបស់គ្រូឧទ្ទេស គឺជាគំរូវិជ្ជាជីវៈសំខាន់សម្រាប់សហគមន៍អប់រំទាំងមូល។



**School Health Development Project for all Cambodian Children (SHCC)**

Email: schoolhealth.cambodia@gmail.com
Website: shcc.u-gakugei.ac.jp
Facebook: https://www.facebook.com/shcc.project

# NEWSLETTER

School Health Development Project for all Cambodian Children

VOLUME 28 | 30 December, 2025

## Closing Ceremony on "SHCC Project - Phase I (2020-2025)" presided over by H.E. Academician HANG CHUON NARON, Deputy Prime Minister, Minister of Education, Youth and Sport








On the morning of 12 December 2025, **H.E. Academician HANG CHUON NARON**, Deputy Prime Minister, Minister of Education, Youth and Sport, presided over the closing ceremony on "School Health Development Project for all Cambodian Children - Phase I (2020-2025)", implemented by Tokyo Gakugei University of Japan. The ceremony was attended by senior leadership of the Ministry of Education, Youth and Sport, Mr. Arikawa Takashi, Executive Director of The Nippon Foundation, Prof. Dr. Asakura Takashi, Leader of the SHCC Project, representatives from Phnom Penh and Battambang Teacher Education Colleges, professors from Tokyo Gakugei University and partner universities, development partners, relevant organizations and ministry officers.







**Published Article:** https://central.ams.com.kh/detail/1276725 ***12 December 2025 | Phnom Penh***



H.E. Academician HANG CHUON NARON,
Deputy Prime Minister, Minister of Education, Youth and Sport.

On this occasion, **H.E. Academician Hang Chuon Naron** expressed his deep appreciation to The Nippon Foundation, the project leader and all relevant stakeholders for their valuable contributions to the successful implementation of the SHCC project, which has significantly contributed to improving student health and learning outcomes. The SHCC project, led by Tokyo Gakugei University in close collaboration with the Department of School Health, Phnom Penh and Battambang Teacher Education Colleges under the Ministry of Education, Youth and Sport and with generous support from The Nippon Foundation, was successfully implemented and completed.

The SHCC project was designed with the objectives of supporting the development of school health curricula and academic programs in higher education institutions, particularly teacher education colleges; providing school health training to primary and secondary school teachers; promoting school health activities; and conducting data collection, monitoring and research to develop core textbooks and training materials for school health lecturers.

The Royal Government of Cambodia has set a clear vision to achieve upper-middle-income country status by 2030 and high-income status by 2050 through the implementation of strategic frameworks aimed at developing a high-quality, productive and healthy workforce.

In this context, the promotion of school health is a critical and indispensable factor in ensuring quality education, increasing student retention and completion rates and achieving national education goals and vision. Student health is a core determinant of learning and a foundation for sustainable national development. Recognizing the close interrelationship between health and education, the integration of school health education into teacher training programs is a vital step in preparing pre-service teachers with the knowledge, skills and professional values necessary to promote student well-being in classrooms and communities.

On behalf of the Ministry of Education, Youth and Sport, H.E. Academician HANG CHUON NARON once again expressed sincere appreciation to the SHCC project team led by Prof. Dr. Asakura Takashi, professors from Tokyo Gakugei University, and partner universities in Japan—Ibaraki University, Jumonji University, Saitama University and Yokohama National University—for their contributions to the development of the core school health curriculum and textbooks, as well as to the leadership and staff of the Department of School Health and the Phnom Penh and Battambang Teacher Education Colleges for their strong commitment and dedicated efforts in implementing the SHCC project with high responsibility and achieving tangible results.



## Brief Welcome Report by SHCC Project Leader

**Prof. Dr. ASAKURA TAKASHI**, SHCC Project Leader. The SHCC Project, implemented by Tokyo Gakugei University with support from The Nippon Foundation, successfully concluded Phase 1 after nearly seven years (2019–2025). Beginning as a small initiative, the project grew into a structured collaboration with PTEC and BTEC, supported by local staff and Japanese academic experts, overcoming early challenges and the COVID-19 pandemic through strong in-person cooperation. Guided by a “middle-up and middle-down” approach, the project focused on strengthening Teacher Education Colleges as key drivers of sustainable improvement in school health education. Major achievements include the development of comprehensive School Health textbook for the primary education 2 credits and a Teacher’s Guidebook lecturers. An extensive capacity building for lecturers through 25 trainings in Cambodia and 4 trainings in Japan. To date, a total of 1,200 student teachers have studied School Health across four cohorts. Among them, 900 graduates from the first three cohorts are now working as teachers across Cambodia and are capable of teaching School Health.


Mr. ASAKURA TAKSHI, Project Leader of SHCC





From 2026, Phase 2 will begin under a new organization, the NGO STEP (School Health Training and Ecohealth Promotion Foundation), which will continue SHCC’s activities with support from The Nippon Foundation, aiming to establish a School Health specialization course in the lower secondary teacher education programs at Phnom Penh and Battambang Teacher Education College.

## Remark by Executive Director of The Nippon Foundation


Mr. ARIKAWA TAKASHI, Executive Director The Nippon Foundation





**Mr. ARIKAWA TAKASHI**, Executive Director of the Department of International Affairs at The Nippon Foundation, highlighted the successful completion of Phase 1 (2020–2025) of the SHCC project. He expressed gratitude to the Ministry of Education, Youth and Sport, Teacher Education Colleges, project partners and stakeholders for their strong cooperation and commitment.

Mr. Arikawa highlighted that the SHCC project has strengthened pre-service teacher training in the new School Health subject, laying the foundation for quality education and cultivating future Cambodian educators.

Looking ahead to Phase 2 (2026–2028) scheduled to begin in January 2026. He continues, as you are well aware, what we external partners can do is only to offer a range of technical and knowledge-based options. For sustainable education development, it is essential that you design your own unique Cambodian teacher training and health education lectures—not merely copying the Japanese style—with your own hands, with the options. He concluded by reaffirming the shared commitment to quality education in Cambodia and expressed anticipation for continued collaboration in the next phase of the project.

# Handover Ceremony of the School Health Textbooks for Lower Secondary Course



**Prof. Dr. ASAKURA TAKASHI**, Project Leader of SHCC handover the School Health Textbooks to **H.E. Academician HANG CHUON NARON.**



**H.E. Academician HANG CHUON NARON** giving an Appreciation Letter to Project Leader of SHCC.



**Mr. ARIKAWA TAKASHI**, Executive Director of The Nippon Foundation, handover the School Health Textbooks to **H.E. Academician HANG CHUON NARON.**



**H.E. Academician HANG CHUON NARON** giving an Appreciation Letter to Director of The Nippon Foundation.

**H.E. Academician HANG CHUON NARON** giving Textbook and Appreciation Letter to **H.E. Dr. CHEA RATHA,** Director of Battambang Teacher Education College.





**H.E. Academician HANG CHUON NARON** giving Textbook and Appreciation Letter to **H.E. Dr. SET SENG,** Director of Phnom Penh Teacher Education College.

# Our 5-Year Journey, Now Documented!









The video highlight the dedication and achievements of **Mr. Hong Sovann**, School Health lecturer at PTEC, and **Ms. Lam Bunmakara**, School Health lecturer at BTEC. Their active participation in the SHCC Project has strengthened their teaching skills, professional expertise, and knowledge in health education, enabling them to more effectively promote the health, safety, and overall well-being of Cambodian students. Both lecturers also express gratitude to the partner universities and supporting organizations that contributed to the successful implementation of the project.

*Scan QR Code to access the VIDEO*

## The Achievement Report: 2020 – 2025









The five-year SHCC Project report provides an overview of the project implementation from 2020 to 2025, with the aim of supporting the Phnom Penh Teacher Education College and the Battambang Teacher Education College in integrating School Health as a new and core subject for primary and lower secondary teacher education. During the five-year period, the SHCC Project carried out key activities, including the development of a detailed curriculum, the preparation of core textbooks, the training of school health lecturers, and the provision of teaching support at teacher education colleges. These efforts have ensured the effective, high-quality, and sustainable implementation of the School Health subject.

*Scan QR Code to access the REPORT*

## Presentation on the “Achievement of Health Education Subject at TECs”





**Ms. LOK SOLINDA**, School Health lecturer of PTEC, highlighted the syllabus and textbook, the management of student health and well-being, professional training programs and field visit and the supported to the two attached schools aiming to strengthen educator capacity and promote the well-being of student teachers.





**Mr. SREY KHIVSOKHOM**, School Health lecturer of BTEC, delivered a comprehensive presentation on the current status of the School Health subject. His presentation covered on training activities, identified key challenges and recommendations and outline future plans aimed to strengthen its implementation of School Health Education.

## Presentation on the Future Plan on “School Health Development Project for all Cambodian Children - Phase II (2026 - 2028)”

**Ms. MASUKO YUKA,** SHCC Project Coordinator presented on the overview of NGO STEP that will be operated from 2026 and the School Health Development Project for all Cambodia Children (SHCC) Phase II (2026–2028), which aims to promote school health education in Cambodia by developing teacher training curricula and strengthening educators’ capacity to improve children’s health and well-being.



## Closing Remark by H.E. Dr. YUNG KUNTHEARITH, Deputy Director of School Health Department, Ministry of Education, Youth and Sport








The Ministry of Education, Youth and Sport places great importance on school health, a sector that continues to receive strong attention and commitment from **H.E. Academician HANG CHUON NARON**, Deputy Prime Minister, Minister of Education, Youth and Sport. Focus on school health is recognized as a crucial pathway for building youth capacity and promoting sustainable education.

Building on over 20 years of experience in implementing various development projects, the SHCC project has been acknowledged as a truly distinctive initiative. In addition to organizing 25 trainings in Cambodia and 4 trainings in Japan, the SHCC project stands out for integrating educational principles with practical implementation and hands-on experience. This integration distinguishes the project from other educational initiatives and ensures results that are actionable and relevant within the Cambodian context.

Moreover, the SHCC project has strengthened a spirit of collaboration and fostered a professional community that is cohesive and mutually supportive. The project has contributed significantly to developing teachers’ competencies and knowledge in line with 21st-century requirements. By effectively implementing national education policies, leveraging skilled human resources, and demonstrating strong commitment, the SHCC project plays a vital role in advancing national priorities in school health and youth education.

## Distribution of Certification presided over by H.E. Academician HANG CHUON NARON, Deputy Prime Minister, Minister of Education, Youth and Sport




### Phnom Penh Teacher Education College


Ms. HOUR KHIM


Ms. LOK SOLINDA


Ms. NAK PECHLEAKHNA


Ms. NOUV SOPHAL


Mr. HONG SOVANN


Ms. CHHAY BONY


Mr. PALL CHAMROEN


Ms. SAN SREYRY


Ms. HOU SAOMOLINE


Ms. CHHOM KUNTHY


Mr. SENG SIHAK

### Battambang Teacher Education College


Ms. LAM BUNMAKARA


Mr. MAO VEASNA


Mr. SREY KHIVSOKHOM


Mr. CHAN RA


Ms. SARY MONIKA


Ms. HENG TOLA


Ms. KEO RAKSMEY


Ms. SAR SOMNEA

## Highlight Video capturing the Key moments from the Closing Ceremony





The Closing Ceremony of the SHCC Project – Phase I (2020–2025) marked key achievements and the valuable contributions of partners and stakeholders over the five-year period. This highlight video showcases important events and collective efforts during the successful completion of the project under the distinguished presidency of **H.E. Academician HANG CHUON NARON**, Deputy Prime Minister, Minister of Education, Youth and Sport.

*Scan QR Code to access the VIDEO*

## The Top 5 Rewards: Perfect Attendance




**Mr. MAO VEASNA (BTEC)**




**Ms. LAM BUNMAKARA (BTEC)**




**Mr. SREY KHIVSOKHOM (BTEC)**




**Ms. OUM RITHSYA (PTEC)**




**Ms. CHHOM KUNTHY (PTEC)**

Dedication in action! The SHCC Project proudly celebrates five standout lecturers who achieved a near-flawless attendance record across our 25-session training sessions. Their consistency and drive set a powerful example for the entire academic community.




**School Health Development Project for all Cambodian Children (SHCC)**

Email: schoolhealth.cambodia@gmail.com
Website: shcc.u-gakugei.ac.jp
Facebook: https://www.facebook.com/shcc.project